


# «តម្លៃវប្បធម៌
# សិល្បៈខ្មែរ៖ ក្បាច់ហៀន»

*ដោយ*
លោក **រ៉េត សាមុត**

២០១៨

## សន្និសីទអន្តរជាតិលើកទី១៤ ស្ដីពីតម្លៃវប្បធម៌អាស៊ីប៉ាស៊ីហ្វិក
## ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨

# «តម្លៃវប្បធម៌សិល្បៈខ្មែរ៖ ក្បាច់ហៀន»

ដោយលោក **វ៉ែត សាមុត**



នៅក្នុងសកលលោកយើងនេះ យើងតែងសង្កេតឃើញសង្គមមួយរីកលូតលាស់រុងរឿងទៅមុខបាន លុះត្រាតែសង្គមនោះបានភ្ជាប់ជីវិតទៅជាមួយជំនឿ និងសាសនា តែសិល្បៈក៏ជាគ្រឿងមួយដែលមិនអាចខ្វះបានពីព្រោះទាំងនេះ គឺជាប្រភព និងជាគ្រឹះដែលនាំឱ្យសង្គម និងជីវិតប្រកបដោយចក្ដីសង្ឃឹម ហើយសេចក្ដីក្សេមក្សាន្ត។

ដោយឡែកនៅក្នុងសង្គមខ្មែរយើងនេះ គឺអាចចាត់ទុកជាប្រទេសដែលបានរៀបចំសង្គមបានល្អតាំងពីយូរលង់មក ចំពោះជំនឿវិញក៏បានប្រសូត្រនិងលាតត្រដាងឱ្យគេដឹងថា មានតាំងតែពី១២០០០ឆ្នាំទៅ៦០០០ឆ្នាំមុនគ្រឹះសករាជ គឺមុនពេលដែលជំនឿសាសនាហិណ្ឌូ និងព្រះពុទ្ធសាសនា មកដល់ខ្មែរមានជំនឿយ៉ាងខ្លាំងទៅលើផ្នែកអរូបិយ ដូចជា ខ្មោច ព្រាយ អសុរកាយ ធ្មប់ អាប ខ្យល់ ទឹក ដី កំដៅ ដុំដំបូក។ល។ ខ្មែរមានការចេះ ស្គាល់ យល់ដឹងពីកម្លាំងនៃបាតុភូតធម្មជាតិ កម្លាំងនៃឥទ្ធិពលធម្មជាតិ ផែនដី ព្រះច័ន្ទ ព្រះអាទិត្យ និងភពនានា ចេះមើលឃើញឋានសួគ៌ ទេវតា ឬ ព្រះអាទិត្យ...។

*(ត្រង់នេះ មានវីដេអូស្ដីពីកញ្ចុំផ្កាយ ខ្យល់គួច ខ្យល់ព្យុះ ទឹកសមុទ្រ ផែនដីវិល និងវត្ថុមួយចំនួនដែលមានសណ្ឋានដូចរបស់ដែលគួចដូចគួចខ្យល ១)។*

បាតុភូតដែលគួចនេះហើយ ដែលធ្វើឱ្យខ្មែរដើមបានយល់ដឹងថា គ្រប់យ៉ាងដែលកើតមក រមែងមានចំណុចចាប់ផ្ដើម ដែលយើងហៅថា "**មេ**" ឬធាតុ។ ប្រសិនបើមិនមានធាតុគ្រប់គ្រាន់ អ្វីៗទាំងនេះវាមិនកើតទេ

ឧទាហរណ៍៖ ដីចំការ ដែលយើងទុកចោល បើសិនជាដីនោះគ្មានកំដៅ គ្មានទឹក គ្មានអុកស៊ីសែននោះទេ ស្មៅ ឬ រុក្ខជាតិ ក៏មិនអាចដុះបានទេ។ ហេតុនេះ ខ្ញុំចង់មានន័យថា គ្រប់យ៉ាងសុទ្ធតែត្រូវផ្សំពីចំណុចផ្តើម។

វិលមកជំនឿខ្មែរដើម គាត់ដឹងថា ភព ផ្កាយ ផែនដី ឬ អ្វីៗជុំវិញនេះ គឺប្រព្រឹត្តទៅដោយចលនា ការកំរើក ការវិល ការកើត ការចាស់ និងការបាត់ទៅវិញ...។ គាត់បង្កើតជាក្បាច់មួយបែបហៅថា "**ក្បាច់ហៀន**" ដែលជានិមិត្តរូបនៃភពផ្កាយ ផែនដី និងជីវិត ជាដើម នោះឡើងមក។

*(ត្រង់នេះមានបង្ហាញពីគំនូរ ៥ផ្ទាំងស្តីអំពី "ក្បាច់ហៀន" យ៉ាងត្រកាល...)។*

តាមរយៈគំនូរក្បាច់ហៀននេះ បង្ហាញឱ្យឃើញថា ចំណុចដំបូងដែលតូចនោះ បង្ហាញពីភាពចាប់ផ្តើម វាប្រៀបដូចជាមេ ឬធាតុដំបូងនៃធម្មជាតិ នៃជីវិត ទាំងភព ទាំងផែនដី ទាំងដួងតារា ដែលចាប់កំណើតមក ហើយក្នុងគំនូរបន្ទាប់ បង្ហាញពីការរីវឌ្ឍធំធាត់ ជរា និងបាត់បង់ទៅវិញ។

សូមជម្រាបថា ក្នុងរចនាបថនៃសិល្បៈខ្មែរទាំង១២ប្រភេទ យើងតែងប្រទះឃើញក្បាច់ហៀននេះត្រូវបានដើរតួយ៉ាងសំខាន់ បីដូចជាចាំជួយតឿននិងក្រើនរំលឹកដល់គ្រប់ជីវិតទាំងអស់ឱ្យយល់ពី "**វដ្ត**" គឺ "**កើត ចាស់ ឈឺ ស្លាប់**" គឺរមែងកើតមានជាបន្តបន្ទាប់។ ក្បាច់នេះ មាននៅគ្រប់ប្រាសាទក្នុងស្រុកខ្មែរ បើមិនមានរាងដូច តែវាមិនដូរទំរង់ទេ។

*(ត្រង់នេះ បង្ហាញពីគំនូរ ពង្រីកក្បាច់ ឬ វីដេអូ ដើម្បីឱ្យកាន់តែយល់ច្បាស់តាមឱកាសដែលមាន)។*

សរុបមក នៅពេលដែលយើងមើលក្បាច់ទាំងឡាយ ដែលមានលក្ខណៈជាក្បាច់ហៀនទោះក្នុង ក្បាច់អង្គរ ក្បាច់ភ្ញីទេស ក្បាច់ភ្ញីវល្លិ៍ ក្បាច់ភ្ញីភ្លើង ក្បាច់ចក ក្បាច់ផ្សេង ក្នុងទំរង់ហៀនឬគូថខ្យងនេះ គឺសុទ្ធសឹងបង្ហាញពីថាមពល ភពផែនដី ពីព្រះ ពីទេវតា ពីនយោបាយ ពីសង្គមពីសេដ្ឋកិច្ច ពីជីវិត ពីធម្មជាតិ ពីសិល្បៈ ពីបាតុភូតគ្រប់យ៉ាង ដែលមានចំណុចចាប់ផ្តើម គឺតែងមានចំណុចនិងបញ្ចប់។

ទាំងនេះ គឺជាការបង្ហាញត្រួសៗស្តីពីក្បាច់ហៀន ឥឡូវនេះ ចូរអស់លោកទៅសង្កេតលើផ្នែកទឹកដែលជាវត្ថុដ៏ពិសិដ្ឋ និងខ្ពង់ខ្ពស់ ដែលគ្រប់ជីវិតនៅក្នុងលោកខ្វះមិនបាន សត្វ មនុស្ស ធម្មជាតិ មិនអាចរស់ ដោយខ្វះទឹក ទឹកជាជីវិត គឺខ្មែរបុរាណ ប្រដូចនឹងក្បាច់ហៀន បើមានទឹក ខ្វះដីមិនបាន ដូចនេះ ទឹក+ដី > ជីវិត។

ទឹក > មេ ស្រី

ដី > បា បុរស រវាងបុរសនិងស្រី ឬ មេនិងបា ត្រូវបានបង្ហាញសានិមិត្តរូបតាមរយៈសត្វល្អូនដូចជា ម្កុ ពស់ នាគ ត្រកួត ថ្លែន ដោយក្នុងចំណោមសត្វទាំងនេះ គេសង្កេតឃើញថា ពស់ នាគ ត្រូវខ្មែរចាត់ទុកជាសត្វមង្គល មានសច្ចៈ មានយុត្តិធម៌ ទៀងត្រង់ ទន់ភ្លន់ ល្វតល្វន់ ស្រការវាសកជាតំណាងឱ្យភាពអមតៈ។

*(ត្រង់នេះមានបង្ហាញពីរបាំអប្សរា អមដោយកាន់អត្ថាធិប្បាយ ពីកាយវិការនៃក្បាច់ហៀនមាន៖*
*ពន្លក ដើម ស្លឹក មែក ជាង ផ្កា ផ្លែ ទុំ ជ្រុះ "វដ្ត")។*